ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ប.ត.ក
P.T.C

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ឯកឧត្តមបណ្ឌិត YAACOB IBRAHIM រដ្ឋមន្ត្រីក្រសួងគមនាគមន៍ និងព័ត៌មាន នៃប្រទេសសិង្ហបុរី **ឯកឧត្តម ត្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** នឹងដឹកនាំគណៈប្រតិភូ អញ្ជើញចូលរួមចូលរួមពិធីបើក "ពិព័រណ៌ផ្លាស់ប្តូរធុរកិច្ចបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន( Infocomm Media Business Exchange : imBX )" និង "វេទិកាថ្នាក់រដ្ឋមន្ត្រីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(ICT)" ពីថ្ងៃទី០១ ដល់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ នៅប្រទេសសិង្ហបុរី។

**"ពិព័រណ៌ផ្លាស់ប្តូរធុរកិច្ចបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន"** គឺជាវេទិកាស្តីពីបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ICT) និងប្រព័ន្ធផ្សព្វផ្សាយ(media) ដ៏ធំបំផុតនៅក្នុងតំបន់អាស៊ី ដែលត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ និងមានការអញ្ជើញចូលរួមពីផ្នែករដ្ឋាភិបាល ថ្នាក់ដឹកនាំធុរកិច្ច និងអ្នកឯកទេសផ្នែកឧស្សាហកម្ម ដើម្បីផ្លាស់ប្តូរគំនិត បង្ហាញពីនវានុវត្តន៍ និងស្វែងរកកាលានុវត្តភាពខាងទីផ្សារ។

ចំណែក **"វេទិកាថ្នាក់រដ្ឋមន្ត្រីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន"** គឺជា វេទិកាកំរិតខ្ពស់ ត្រូវបានផ្តួចផ្តើម និងប្រារព្ធធ្វើឡើងមួយឆ្នាំម្តង ដោយក្រសួងគមនាគមន៍និងព័ត៌មានសិង្ហបុរី មានការអញ្ជើញចូលរួមពីថ្នាក់រដ្ឋមន្ត្រី តំណាងជាន់ខ្ពស់នៃបណ្តាប្រទេសជាច្រើន អ្នករៀបចំតាក់តែងគោលនយោបាយ និងផ្នែកឯកជនដែលពាក់ព័ន្ធ ដើម្បីពិភាក្សា ផ្លាស់ប្តូរយោបល់គ្នាអំពីចំណុចគន្លឹះ និងនិន្នាការសកលនៃវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន(ICT) ដែលជះឥទ្ធិពលដល់សង្គម និងសេដ្ឋកិច្ចបច្ចុប្បន្ន។

**"វេទិកាថ្នាក់រដ្ឋមន្ត្រីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន"** ឆ្នាំ២០១៥ក្រោមប្រធានបទ ***"ការកសាងសង្គមជាតិមួយដ៏ឆ្លាតវៃ៖ នវានុវត្តន៍ឆ្លងតាមរយៈបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន(ICT)"*** នេះ នឹងពិភាក្សាគ្នាស៊ីជម្រៅលើប្រធានបទធំៗ បី គឺ៖

ទី១-នវានុវត្តន៍ដើម្បីសង្គមជាតិឆ្លាតវៃ (Innovation for Smart Nation),

ទី២-តួនាទីរដ្ឋាភិបាលក្នុងសង្គមជាតិឆ្លាតវៃ (The Role of Government in Smart Nation),និង

ទី៣-កិច្ចសន្ទនាជាន់ខ្ពស់ស្តីពីសង្គមជាតិឆ្លាតវៃ (High-level Dialogue on Smart Nation)

**រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០១៥**

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ(៨៥៥) ២៣-៧២៤៨០៩/៤២៨២៤៦
ទូរសារ(៨៥៥) ២៣-៤២៦៥៤១/៤២៦០០៥/៧២៤៨០៩